ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ
លេខ:.................អសជ/.....

# របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការ
# ស្តីពីការគ្រប់គ្រងថវិកា
# ក្រុង-ស្រុកនៃរដ្ឋបាលខេត្តកែប

## ការិយបរិច្ឆេទ ២០២២

អគារលេខ ៥ ផ្លូវឌួងងៀប៣ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
Tel:(855-23) 885 900, (855-12) 737 622 Fax: (855-023) 885 900
# 5, St. Duong Ngeab 3, Sangkat Tekthla, Khan Sensok, Phnom Penh, CAMBODIA
E-mail: naakh@naa.gov.kh website: www.naa.gov.kh

**សេចក្តីសង្ខេប**

អនុលោមតាមមាត្រា២ មាត្រា៣ និងមាត្រា៩ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ អាជ្ញាធរសវនកម្មជាតិមានភារកិច្ចធ្វើសវនកម្មលើបណ្តាក្រសួង ស្ថាប័ន និងរាជធានី ខេត្ត។ អាជ្ញាធរសវនកម្មជាតិបានជ្រើសយករដ្ឋបាលក្រុងកែប និងរដ្ឋបាលស្រុកដំណាក់ចង្អើរ នៃខេត្តកែប សម្រាប់ធ្វើសវនកម្មលើកិច្ចប្រតិបត្តិការស្តីពីការគ្រប់គ្រងថវិកាក្រុង ស្រុក សម្រាប់ការិយបរិច្ឆេទ២០២២ និងឆ្នាំពាក់ព័ន្ធ ក្នុងគោលបំណងបង្កើននូវភាពសន្សំសំចៃ ប្រសិទ្ធភាព និងប្រសិទ្ធផល ដោយផ្សារភ្ជាប់ទៅនឹងបរិយាប័ន្ននៃការអនុវត្តក្របខណ្ឌហិរញ្ញវត្ថុសាធារណៈជាមួយនឹងមូលនិធិថវិកាក្រុង ស្រុក សម្រាប់អភិវឌ្ឍគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្លូវថ្នល់នៅថ្នាក់មូលដ្ឋាន កម្រិតរដ្ឋបាលក្រុង ស្រុក។

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ ស្តីពីការគ្រប់គ្រងថវិកានៅរដ្ឋបាលក្រុងកែប និងរដ្ឋបាលស្រុកដំណាក់ចង្អើរ នៃខេត្តកែប សម្រាប់ការិយបរិច្ឆេទ២០២២ និងឆ្នាំពាក់ព័ន្ធ ដើម្បីវាយតម្លៃអំពីភាពសន្សំសំចៃ ប្រសិទ្ធភាព និងប្រសិទ្ធផល នៃការគ្រប់គ្រងថវិកានៅរដ្ឋបាលក្រុង ស្រុក។

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ ស្តីពីការគ្រប់គ្រងថវិកានៅរដ្ឋបាលក្រុងកែប និងរដ្ឋបាលស្រុកដំណាក់ចង្អើរ នៃខេត្តកែប សម្រាប់ការិយបរិច្ឆេទ២០២២ និងឆ្នាំពាក់ព័ន្ធ ដោយផ្តោតជាសំខាន់លើ (១) លក្ខខណ្ឌនៃគម្រោងថវិកាក្រុង ស្រុក ព្រមទាំងដំណើរការ នីតិវិធី និងវិធីសាស្ត្រនៃការគ្រោងចំណូល ដោយរួមទាំងចំណូលពីការបែងចែកក្នុងអត្រា៤% នៃចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្ត និងថវិកាសម្រាប់ចំណាយលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្លូវថ្នល់ និង (២) ការអនុវត្តថវិកា ដោយរួមមានដំណើរការ នីតិវិធី និងវិធីសាស្ត្រនៃការប្រមូលចំណូល និងការអនុវត្តចំណាយថវិកាក្រុង ស្រុក។

តាមរយៈការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការលើប្រធាននេះ អាជ្ញាធរសវនកម្មជាតិសូមបង្ហាញជូននូវលទ្ធផលសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

**១. ការមិនបានរៀបចំផែនការយុទ្ធសាស្ត្រថវិកាក្រុង ស្រុក**

តាមគោលការណ៍នៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ជាទូទៅគម្រោងថវិកាប្រចាំឆ្នាំនីមួយៗរបស់រដ្ឋបាលក្រុង ស្រុក ត្រូវរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុកនីមួយៗ ដោយផ្អែកលើមូលដ្ឋានផែនការយុទ្ធសាស្ត្រថវិកា ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ដែលអនុម័តដោយក្រុមប្រឹក្សាក្រុងស្រុក។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវចេញសេចក្តីណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាដល់រដ្ឋបាលក្រុង ស្រុក ដើម្បីឱ្យរដ្ឋបាលក្រុង ស្រុក រៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន ឱ្យបានទាន់ពេលវេលា។

តាមការពិនិត្យគម្រោងថវិកាឆ្នាំ២០២២ របស់រដ្ឋបាលក្រុងកែប និងរដ្ឋបាលស្រុកដំណាក់ចង្អើរ ដែលអភិបាលនៃគណៈអភិបាលខេត្តកែបបានផ្តល់អនុលោមភាពជូនរដ្ឋបាលក្រុង ស្រុក ខាងលើនេះ គឺមិនភ្ជាប់ផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួនឡើយ។ បើទោះជា ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាក្រុង ស្រុក ត្រូវបានណែនាំឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗ អនុវត្តតាំងពីឆ្នាំ២០១២ក៏ដោយ។

**២. ការបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្តជូនរដ្ឋបាលក្រុង ស្រុក មិនទាន់ត្រឹមត្រូវ**

រដ្ឋបាលក្រុង ស្រុក ត្រូវរៀបចំគម្រោងចំណូលដោយផ្អែកលើតួលេខដែលបានវិភាជពីមូលនិធិក្រុង ស្រុក ព្រមទាំងថវិកាឧបត្ថម្ភពីថ្នាក់ជាតិសម្រាប់ចំណាយអនុវត្តមុខងារនៃការិយាល័យជំនាញរបស់មន្ទីរជំនាញរាជធានី ខេត្ត ដែលបានធ្វើសមាហរណកម្មចូលក្នុងរចនាសម្ព័ន្ធក្រុង ស្រុក ដែលមានវិស័យចំនួន២០។ ដោយឡែក ចំពោះចំណូលពីការចែករំលែកនៃចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្ត ក្នុងអត្រា៤% ចាប់ពីឆ្នាំ២០២០ ជូនរដ្ឋបាលក្រុង ស្រុក សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវរៀបចំប្រកាសស្តីពីការបន្ថែមឥណទានជូនរដ្ឋបាលក្រុង ស្រុក នៅដើមឆ្នាំថវិកា ដោយត្រូវបោះផ្សាយអាណត្តិឧបត្ថម្ភធនជូនមូលនិធិក្រុង ស្រុក សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ ជា០៤លើក តាមរយៈរដ្ឋបាលខេត្ត។

តាមការពិនិត្យជាក់ស្តែង រដ្ឋបាលក្រុងកែប និងរដ្ឋបាលស្រុកដំណាក់ចង្អើរ បានទទួលឥណទានថវិកាពីឆ្នាំ២០២០-២០២២ សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន ដែលជាប្រភពឧបត្ថម្ភពីរដ្ឋបាលខេត្តនូវចំណូលពីការចែករំលែកក្នុងអត្រា៤% នៃចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្តកែប មិនទាន់បានត្រឹមត្រូវឡើយ ក្នុងនោះ (១) ឆ្នាំ២០២០ ទទួលបានថវិកាចំនួន**៧៨ ០០០ ០០០**រៀល ក្នុងចំណោមថវិកាដែលត្រូវផ្តល់ចំនួន**២៣៦ ៣៦៨ ០៤៩**រៀល (២) ឆ្នាំ២០២១ ទទួលបានថវិកាចំនួន**៦៦ ០០០ ០០០**រៀល ក្នុងចំណោមថវិកាដែលត្រូវផ្តល់ចំនួន**៤១៧ ៦៦៨ ១៤៣**រៀល និង (៣) ឆ្នាំ២០២២ ទទួលបានថវិកាចំនួន**៦៦ ០០០ ០០០**រៀល ក្នុងចំណោមថវិកាដែលត្រូវផ្តល់ចំនួន**២៧៦ ៥៦៦ ៦០០**រៀល។

**៣. ការមិនទាន់ផ្តល់ឥណទានថវិកាសម្រាប់ចំណាយមូលធនជូនរដ្ឋបាលក្រុង ស្រុក**

តាមគោលការណ៍ទូទៅ ថវិការបស់រដ្ឋបាលក្រុង ស្រុក ត្រូវបានរៀបចំឡើងជាពីរផ្នែក គឺផ្នែកទី១ : ចំណូលចរន្ត និងចំណាយចរន្ត និងផ្នែកទី២ : ចំណូលមូលធន និងចំណាយមូលធន ហើយចំពោះចំណាយមូលធនសម្រាប់ចំណាយអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្លូវថ្នល់ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់តាមជំពូក២១ គណនី២១០៤ និងអនុគណនី២១០៤១ ស្តីពីហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់-ផ្លូវទឹក។

តាមការពិនិត្យរបាយការណ៍ស្តីពីការបិទបញ្ជីថវិកាពីឆ្នាំ២០២០-២០២២ របស់រដ្ឋបាលក្រុងកែប និងរដ្ឋបាលស្រុកដំណាក់ចង្អើរ បានបង្ហាញថា រដ្ឋបាលក្រុងកែប និងរដ្ឋបាលស្រុកដំណាក់ចង្អើរ ពុំទាន់ទទួលបានឥណទានថវិកាសម្រាប់ចំណាយមូលធន ដើម្បីអភិវឌ្ឍនូវហេដ្ឋានរចនាសម្ព័ន្ធរូបវន្តរបស់ខ្លួននៅឡើយ។

តាមលទ្ធផលសវនកម្មដែលបានបរិយាយក្នុងជំពូកទី៣ និងសេចក្ដីសន្និដ្ឋានសវនកម្ម ដែលបានបង្ហាញក្នុងជំពូកទី៤ ខាងក្រោម អាជ្ញាធរសវនកម្មជាតិសូមផ្ដល់អនុសាសន៍ជូនក្រសួងមានសមត្ថកិច្ច និងរដ្ឋបាលពាក់ព័ន្ធស្ដីពីការគ្រប់គ្រងថវិកានៅរដ្ឋបាលក្រុងកែប និងរដ្ឋបាលស្រុកដំណាក់ចង្អើរ សម្រាប់ការិយបរិច្ឆេទ២០២២ និងឆ្នាំពាក់ព័ន្ធ ដូចតទៅ៖

១. រដ្ឋបាលក្រុងកែប និងរដ្ឋបាលស្រុកដំណាក់ចង្អើរ គួរស្នើសុំគោលការណ៍ពីរដ្ឋបាលខេត្តជំរុញឱ្យនាយកទីចាត់ការហិរញ្ញវត្ថុ និងប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជួយបណ្ដុះបណ្ដាលអំពីនីតិវិធីនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាក្រុង ស្រុក ដល់ថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុក និងមន្ត្រីពាក់ព័ន្ធ ដើម្បីឱ្យរដ្ឋបាលក្រុង ស្រុក អាចមានសមត្ថភាពសមស្របក្នុងការចូលរួមអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥ ដែលជាអភិក្រមពីក្រោមឡើងលើ។

២. រដ្ឋបាលក្រុងកែប និងរដ្ឋបាលស្រុកដំណាក់ចង្អើរ គួរស្នើសុំគោលការណ៍ពីរដ្ឋបាលខេត្ត ដើម្បីឱ្យនាយកទីចាត់ការហិរញ្ញវត្ថុ និងប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្ដល់តួលេខនៃចំណូលសារពើពន្ធប្រចាំឆ្នាំនីមួយៗរបស់រដ្ឋបាលខេត្តកែប សម្រាប់ធ្វើជាមូលដ្ឋាននៃការគណនាចំណូលពីការបែងចែកក្នុងអត្រា៤% ជូនរដ្ឋបាលក្រុង ស្រុក នៅក្នុងឆ្នាំអនុវត្តថវិកា និងជាមូលដ្ឋានសម្រាប់ផ្ទៀងផ្ទាត់ថាខ្លួនបានទទួលចំណូលនេះបានត្រឹមត្រូវ និងគ្រប់ចំនួនតាមគោលការណ៍កំណត់ដែរ ឬទេ។

៣. រដ្ឋបាលក្រុងកែប និងរដ្ឋបាលស្រុកដំណាក់ចង្អើរ គួរស្នើសុំគោលការណ៍ពីរដ្ឋបាលខេត្ត ដើម្បីឱ្យនាយកទីចាត់ការហិរញ្ញវត្ថុ និងប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជួយណែនាំអំពីនីតិវិធីនៃការគ្រោងថវិកាសម្រាប់ចំណាយមូលធន ដើម្បីមានមូលដ្ឋានច្បាស់លាស់ក្នុងការស្នើសុំថវិកាសម្រាប់ចំណាយមូលធន ដែលជាតម្រូវការចាំបាច់ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្លូវថ្នល់ ដើម្បីបំពេញតាមតម្រូវការក្នុងអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងតំបន់របស់ខ្លួនឱ្យកាន់តែប្រសើរឡើង។

ទន្ទឹមនឹងនេះ ដើម្បីធានាបាននូវការអនុវត្តគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រនានា ដែលបានចាប់ផ្ដើមពីយុទ្ធសាស្ត្រត្រីកោណ យុទ្ធសាស្ត្រចតុកោណ និងបន្តដល់យុទ្ធសាស្ត្របញ្ចកោណ ព្រមទាំងកំណែទម្រង់នានា ជាពិសេសកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាកំណែទម្រង់លើវិស័យរដ្ឋបាលសាធារណៈ ដើម្បីសម្រេចបាននូវគោលដៅចម្បងៗរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានកំណត់។